# សេចក្តីសង្ខេបរួម

## បរិបទ និងការពិពណ៌នាគម្រោង

នៅក្នុងសម័យខ្មែរក្រហម ប្រជាជនកម្ពុជាទទួលរងនូវទម្រង់ច្រើនប្រភេទនៃការធ្វើអំពើហិង្សាផ្លូវភេទ ក្នុងនោះរួមមាន ការរំលោភផ្លូវភេទជាក្រុម មុនយកទៅសម្លាប់ ការកាត់ប្រដាប់ភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងការធ្វើឲ្យទៅជាទាសករ និងអាពាហ៍ពិពាហ៍ដោយបង្ខំ។ ក្នុងឆ្នាំ២០០១ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ អ.វ.ត.ក) ជាតុលាការមួយសម្រាប់ជំនុំជម្រះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត ដែលបានអនុវត្តក្នុងអំឡុងសម័យខ្មែរក្រហម។ សំណុំរឿង ០០២/០២ បានរាប់បញ្ចូលទម្រង់ជាក់លាក់មួយនៃអំពើហិង្សាផ្លូវភេទ នោះគឺ “អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទកើតឡើងក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ” ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន។ ឧក្រិដ្ឋកម្មទាំងនេះស្ថិតក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។

អ.វ.ត.ក គឺជាតុលាការកូនកាត់ដំបូងគេបង្អស់ អនុវត្តយន្តការ ដោយមានការចូលរួមរបស់ដើម បណ្តឹងរដ្ឋប្បវេណី និងផ្តល់ឲ្យអ្នកនៅរស់រានមានជីវិតនូវសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីបន្ថែមទៀត ដោយអនុញ្ញាតឲ្យរួមចំណែកដ៏សកម្ម ក្នុងដំណើរការនីតិវិធីច្បាប់ និងសិទ្ធិទទួលបានសំណងផ្លូវចិត្ត និងសមូហភាព។ “វិធានការក្រៅប្រព័ន្ធតុលាការ” គឺជាយន្តការបន្ថែមមួយទៀតផ្តល់ឲ្យអ្នកនៅរស់រានមាន ជីវិតពីរបបខ្មែរក្រហមទាំងអស់នូវទម្រង់យុត្តិធម៌ខ្លះ ដោយពុំពាក់ព័ន្ធនឹងឋានៈរបស់ពួកគាត់ នៅចំពោះមុខ អ.វ.ត.ក ឡើយ។

គម្រោងដែលកំពុងត្រូវបានវាយតម្លៃនេះតំណាងឲ្យគម្រោងមានលក្ខណៈយូរអង្វែង និងទូលំទូលាយបំផុត ក្នុងចំណោមគម្រោងផ្តល់សំណងរបស់អ.វ.ត.ក និងវិធានការក្រៅប្រព័ន្ធតុលាការ ហើយគំនិតផ្តួចផ្តើមចម្បងគឺ ដើម្បីឆ្លុះបញ្ចាំងអំពីអំពើហិង្សាផ្លូវភេទ ដែលកើតមានក្នុងសម័យខ្មែរក្រហម ក្នុងនោះរាប់ទាំង អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងប្រទេសកម្ពុជាផងដែរ។

គម្រោងនេះរៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក អង្គការចិត្តសង្គម អន្តរវប្បធម៌ (អង្គការធីភីអូ) និងអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (អង្គការស៊ីឌីភី) ដោយមានកិច្ចសហប្រតិបត្តិការជាមួយ និងតាមរយៈថវិកាពីមូលនិធិអង្គការសហប្រជាជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី (UNTF)។

ដំណាក់កាលទីមួយនៃគម្រោង ពីខែតុលា ឆ្នាំ២០១១ ដល់ ខែវិច្ឆិកា ឆ្នាំ២០១៤ ទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់មួយចំនួនធំ។ យ៉ាងណាមិញ ឃើញថា មានភស្តុតាងយ៉ាងច្បាស់ ដែលតម្រូវឲ្យបន្តពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់គម្រោងបន្ថែមទៀត។ ដូច្នេះ ដំណាក់កាលទីពីរនៃគម្រោងក៏ចាប់ដំណើរការពីខែមករា ឆ្នាំ២០១៦ រហូតដល់ ខែមេសា ឆ្នាំ២០១៩ ដោយមានការឧបត្ថម្ភថវិកាប្រមាណ ១.០០០.០០០ ដុល្លារពីមូលនិធិអង្គការសហប្រជាជាតិ ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងបដិភាគប្រមាណ ២៣៤.០០០ដុល្លារពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

គម្រោងនេះត្រូវបានអនុវត្តនៅទូទាំងប្រទេស និងជាមួយដើមបណ្តឹងរដ្ឋប្បវេណីគោលដៅ ដែលជាស្ត្រីទាំងអស់ ចំនួន២២០០នាក់ ក្នុងសំណុំរឿង០០២ ក៏ដូចជាដើមបណ្តឹងបុរសចំនួន២៤០នាក់ ជាអ្នកទទួលផលប្រយោជន៍ផ្ទាល់ពីគម្រោង។ ជាពិសេស គម្រោងចាប់យកដើមបណ្តឹងរដ្ឋប្បវេណីគោលដៅ ដែលត្រូវបានទទួលស្គាល់ ផ្អែកលើបទចោទអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ ដែលកើតឡើងក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយសារតែពួកគាត់ប្រឈមនឹងឧបសគ្គខ្ពស់ក្នុងដំណើរការយុត្តិធម៌អន្តរកាល។ អ្នកទទួលប្រយោជន៍ផ្ទាល់ពីគម្រោងផ្សេងៗទៀត រួមមានស្ត្រីចំនួន៦៣៣នាក់ និងបុរស១៦២នាក់ ដែលជាអ្នកនៅរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទក្នុងសម័យខ្មែរក្រហម តែមិនត្រូវបានទទួលស្គាល់ជាដើម បណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអ.វ.ត.ក។

អ្នកទទួលប្រយោជន៍ប្រយោលពីគម្រោង រួមមានតំណាងដើមបណ្តឹងរដ្ឋប្បវេណី សមាជិកនៃអង្គការតាមសហគមន៍ អ្នកជំនាញផ្នែកអប់រំ អ្នកជំនាញផ្នែកច្បាប់នៃអ.វ.ត.ក បុគ្គលិកមកពីស្ថាប័នក្នុង និងក្រៅរដ្ឋាភិបាល មេធាវីកម្ពុជា កងកម្លាំងឯកសណ្ឋាន បុគ្គលិកផ្នែកសុខាភិបាល និងសាធារណជនទូទៅ។

## ភាពឧតក្តភាព

**គោលដៅគម្រោង**៖ ដើមបណ្តឹងរដ្ឋប្បវេណីដែលជាស្ត្រីនៅអ.វ.ត.ក ជាពិសេស អ្នកនៅរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម អនុវត្តយ៉ាងពេញលេញនូវសិទ្ធិទទួលបានយុត្តិធម៌អន្តរកាល និងទទួលបានសេវាផ្លូវចិត្តកាន់តែប្រសើរ និងការស្តារនីតិសម្បទា ត្រឹមចុងឆ្នាំ២០១៨។

**លទ្ធផលទី១**៖ បុគ្គលិកអ.វ.ត.ក សមាជិក/សមាជិកាគណៈមេធាវី និស្សិតនីតិសាស្ត្រ និងអង្គការដៃគូមានឥរិយាបទ និងអាកប្បកិរិយាកាន់តែប្រសើរចំពោះតម្រូវការរបស់អ្នករស់រានមានជីវិតនៃអំពើហិង្សាផ្លូវភេទ ដើម្បីផ្តល់សេវាកម្មកាន់តែប្រសើរ។

- លទ្ធផលបឋមទី១.១៖ បុគ្គលិកអ.វ.ត.ក និងអង្គការដៃគូមានចំណេះដឹងកាន់តែច្រើន និងរឹងមាំស្តីពីអំពើហិង្សាផ្លូវភេទ និងអាចយកទៅអនុវត្តក្នុងការងារពួកគេបាន។
- លទ្ធផលបឋមទី១.២៖ សមាជិក/សមាជិកាគណៈមេធាវី និងនិស្សិតនីតិសាស្ត្រមានចំណេះដឹងកាន់តែច្រើន ទាក់ទងនឹងភាពរសើបយេនឌ័រក្នុងជំនាញរបស់ពួកគេ។

**លទ្ធផលទី២**៖ ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាស្ត្រី ពិសេសអ្នកនៅរស់រានពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ទទួលបានធនធាន និងការគ្រប់គ្រងរឿងក្តីប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថា ការចូលរួមរបស់ពួកគាត់នៅតុលាការ និងក្នុងសកម្មភាពពាក់ព័ន្ធនៅក្រៅតុលាការ គឺមានអត្ថន័យជ្រាលជ្រៅ ដោយថា រឿងរ៉ាវរបស់ពួកគាត់ត្រូវបានគេដឹងឮ ហើយពួកគាត់ពេញចិត្តនឹងដំណោះស្រាយ។

- លទ្ធផលបឋមទី២.១៖ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកនៅរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ ដែលជាស្ត្រី មានតំណាងផ្លូវច្បាប់ និងមានមធ្យោបាយសមស្រប ដើម្បីចូលរួមស្តាប់សវនាការជំនុំជម្រះក្តីនៅអ.វ.ត.ក។
- លទ្ធផលបឋមទី២.២៖ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកនៅរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ ដែលជាស្ត្រី មានចំណេះដឹងផ្នែកច្បាប់កាន់តែរឹងមាំក្នុងដំណើរការនីតិវិធី។

**លទ្ធផលទី៣**៖ សាធារណជន សហគមន៍ និងមន្ត្រីរាជការ មានការយល់ដឹងកាន់តែប្រសើរពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ ដែលកើតឡើងក្នុងអំឡុងរបបខ្មែរក្រហម និងទំនាក់ទំនងរបស់វានឹងបញ្ហាយេនឌ័របច្ចុប្បន្ន ដូច្នេះឥរិយាបទ អាកប្បកិរិយា បទអន្តរាគមន៍ និងគោលនយោបាយ មានលក្ខណៈប្រសើរឡើង និងកាន់តែរសើបចំពោះតម្រូវការរបស់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ។

- លទ្ធផលបឋមទី៣.១៖ សាធារណជនទូទៅកាន់តែយល់ដឹងអំពីអំពើហិង្សាផ្លូវភេទក្នុងសម័យខ្មែរក្រហម និងទំនាក់ទំនងរបស់វានឹងបញ្ហាយេនឌ័របច្ចុប្បន្ន តាមរយៈការសន្ទនា និងផ្តល់ព័ត៌មានជាសាធារណៈ។
- លទ្ធផលបឋមទី៣.២៖ ស្ថាប័នរដ្ឋពាក់ព័ន្ធទទួលបានព័ត៌មានពេញលេញស្តីពីអំពើហិង្សាផ្លូវភេទ ដែលកើតឡើងក្នុងអំឡុងរបបខ្មែរក្រហម និងទំនាក់ទំនងរបស់វានឹងបញ្ហាយេនឌ័របច្ចុប្បន្ន និងកាន់តែផ្តោតអារម្មណ៍ទៅលើបញ្ហាទាំងនេះ។
- លទ្ធផលបឋមទី៣.៣៖ ព័ត៌មានស្តីពីអំពើហិង្សាផ្លូវភេទ ដែលកើតឡើងក្នុងអំឡុងរបបខ្មែរក្រហម សិទ្ធិស្ត្រី និងឧទាហរណ៍ស្តីពី "ការអនុវត្តល្អៗ" សម្រាប់វិធានការយុត្តិធម៌អន្តរកាល ដែលមានលក្ខ

ណៈរសើបយេនឌ័រ ត្រូវបានចងក្រងទុកជាឯកសារ ហើយសាធារណជនអាចចូលមើលព័ត៌មានទាំងនេះបាន។

**លទ្ធផលទី៤៖** សុខភាពផ្លូវចិត្ត និងការគាំទ្រគ្នាទៅវិញទៅមកក្នុងចំណោមជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលជាស្ត្រី មានលក្ខណៈកាន់តែប្រសើរឡើង។

- លទ្ធផលបឋមទី៤.១៖ បុគ្គល ដែលជាធនធានប្រចាំនៅតាមសហគមន៍ត្រូវបានកំណត់អត្តសញ្ញាណ ជ្រើសរើស និងបណ្តុះបណ្តាលជាមូលដ្ឋានស្តីពីសុខភាពផ្លូវចិត្ត។
- លទ្ធផលបឋមទី៤.២៖ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ដែលជាស្ត្រីមានសុខភាពផ្លូវចិត្តកាន់តែប្រសើរ តាមរយៈសេវាព្យាបាលការប៉ះទង្គិចផ្លូវចិត្ត ក្នុងនោះរួមមានការព្យាបាលតាមបែបធ្វើសក្ខីកម្ម/និទានរឿង ក្រុមជួយខ្លួនឯង ការផ្តល់ប្រឹក្សាតាមទូរស័ព្ទ និងការព្យាបាលជំងឺវិកលចរិត។
- លទ្ធផលបឋមទី៤.៣៖ ប្រជាពលរដ្ឋចំនួន១០០គ្រួសារ (អ្នកនៅរស់រានមានជីវិត ឬកូនៗពួកគាត់) មានមធ្យោបាយកាន់តែប្រសើរក្នុងការគាំទ្រដល់ជីវភាពរស់នៅរបស់ពួកគាត់។

## គោលបំណង និងវត្ថុបំណងវាយតម្លៃ

អង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក បានផ្តល់អាណត្តិ និងការវាយតម្លៃបញ្ចប់គម្រោងដោយអ្នកជំនាញពីខាងក្រៅ ស្របតាមលក្ខខណ្ឌនៃមូលនិធិអង្គការសហប្រជាជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី។ គោលដៅចម្បងនៃការវាយតម្លៃនេះ គឺផ្តល់ការពិនិត្យលើការអនុវត្តគម្រោង និងកំណត់អត្តសញ្ញាណ និងចងក្រងទុកនូវបទពិសោធន៍ និងមេរៀនល្អៗ ដែលបានរៀនសូត្រកន្លងមក។ ការវាយតម្លៃនេះមានបំណងផ្តល់គណនេយ្យភាព និងតម្លាភាពជូនដល់អ្នកទទួលប្រយោជន៍ពីគម្រោង ម្ចាស់ជំនួយ អ្នកគ្រប់គ្រងគម្រោង ស្ថាប័នពាក់ព័ន្ធទាំងក្នុង និងក្រៅរដ្ឋាភិបាល និងសាធារណជន។ លទ្ធផលនឹងត្រូវបានប្រើប្រាស់ដើម្បីផ្តល់ជាព័ត៌មានដល់ទិសដៅបន្តអនុវត្តគម្រោងចាស់ៗ ឬសកម្មភាពថ្មីៗនៃអង្គការដៃគូអនុវត្តគម្រោង និងផ្តល់ជាភស្តុតាងសម្រាប់សំណើសុំថវិកា ដើម្បីគាំទ្រសកម្មភាពបែបនេះទៀត។

តាមលក្ខណៈវិនិច្ឆ័យនៃបទដ្ឋាន OECD DAC ពាក់ព័ន្ធនឹងទំនាក់ទំនង ប្រសិទ្ធភាព ប្រសិទ្ធផល ចីរភាព ផលប៉ះពាល់ និងការអភិវឌ្ឍចំណេះដឹង វត្ថុបំណងនៃការវាយតម្លៃ ដូចបង្ហាញក្នុងលក្ខខណ្ឌការងារ រួមមាន៖

- វាយតម្លៃគម្រោងទាំងមូល ពិចារណាលើប្រសិទ្ធភាព ទំនាក់ទំនង ប្រសិទ្ធផល ចីរភាព ផលប៉ះពាល់ និងការអភិវឌ្ឍចំណេះដឹង ដោយផ្តោតលើការវាយតម្លៃសមិទ្ធផលនៅកម្រិតគោលដៅ និងលទ្ធផល។
- កំណត់ថាតើលទ្ធផលរួមចំណែកដល់គោលដៅទូទៅរបស់គម្រោងដែរ ឬទេ?
- រិះរកមេរៀនសំខាន់ៗ និងកំណត់ការអនុវត្តល្អៗ សម្រាប់រៀនសូត្រ។
- កំណត់សមិទ្ធផល និងចន្លោះប្រហោងរបស់គម្រោង។
- ផ្តល់ជាអនុសាសន៍ និងការអនុវត្តល្អៗ ដែលអាចប្រើប្រាស់ក្នុងការរៀបចំកម្មវិធីនៅថ្ងៃអនាគត។

អ្នកអានរបាយការណ៍វាយតម្លៃនេះ រួមមាន អង្គភាពគាំពារជនរងគ្រោះ និងអង្គការធីភីអូ អង្គការដៃគូអនុវត្តគម្រោងរបស់អ.វ.ត.ក និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ដែលសកម្មក្នុងការងារយុត្តិធម៌អន្តរកាល និងអំពើហិង្សាផ្លូវភេទ ម្ចាស់ជំនួយជាតិ និងអន្តរជាតិ ក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិសម្រាប់ស្ត្រី ។

ដូចគ្នាដែរ ការវាយតម្លៃនេះមានគោលដៅផ្តល់ជាព័ត៌មាន ពាក់ព័ន្ធនឹងគោលនយោបាយ និងការអនុវត្តនៃស្ថាប័នយុត្តិធម៌អន្តរជាតិ ដោយរួមចំណែកដល់មូលដ្ឋានភស្តុតាង តាមរយៈការកំណត់នូវមេរៀន និងការអនុវត្តល្អៗ។

គំហើញពីការវាយតម្លៃនេះត្រូវបានបង្ហាញ ក្នុងអំឡុងសិក្ខាសាលាខ្នាតធំមួយ ដែលមានការចូលរួមពីសំណាក់បុគ្គលិកក្នុងផ្នែកផ្សេងៗគ្នានៃអង្គការដៃគូ តំណាងអង្គការក្នុង និងក្រៅរដ្ឋាភិបាល និងអ្នកជំនាញ។

# វិធីសាស្ត្រវាយតម្លៃ

វិធីសាស្ត្រចម្រុះមួយ ត្រូវបានប្រើប្រាស់ ដើម្បីអនុញ្ញាតឲ្យមានការផ្ទៀងផ្ទាត់ទាំងគំហើញតាមបែបគុណភាព និងគំហើញតាមបែបបរិមាណ។ យុទ្ធសាស្ត្រប្រមូលទិន្នន័យ រួមមានការស្រាវជ្រាវឯកសារពាក់ព័ន្ធនៅការិយាល័យ បទសម្ភាសន៍ជាលក្ខណៈបុគ្គល ពិភាក្សាជាក្រុម ការអង្កេតស្ដីពីអ្នកទទួលប្រយោជន៍ពីគម្រោង ការចុះមូលដ្ឋានផ្ទាល់ និងការអង្កេតដែលមានការចូលរួម។ ការវាយតម្លៃនេះត្រូវបានរៀបចំក្រោយពេលបញ្ចប់ការអង្កេត តែយ៉ាងណាមិញ លទ្ធផលនៃការវាយតម្លៃនេះត្រូវបានប្រៀបធៀបនឹងទិន្នន័យមូលដ្ឋាន និងលទ្ធផលតាមដានរបស់គម្រោង។

ទិន្នន័យត្រូវបានប្រមូលដោយទីប្រឹក្សាជាតិពីរនាក់ និងអន្តរជាតិម្នាក់ ចាប់ពីថ្ងៃទី១២ ខែតុលា រហូតដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ និងក្នុងខែមិថុនា ឆ្នាំ២០១៩ ដោយសារតែការបន្តអនុវត្តគម្រោង។

ជាសរុប ទីប្រឹក្សាវាយតម្លៃបានធ្វើបទសម្ភាសជាមួយអ្នកផ្ដល់ចម្លើយចំនួន៨៤នាក់ (ស្ត្រី៤៣នាក់ និងបុរស៤១នាក់)។ ការពិភាក្សាជាក្រុមចំនួន១០ត្រូវបានធ្វើឡើង ដោយមានអ្នកចូលរួមសរុបចំនួន៦៣នាក់ (ស្ត្រី៤៦នាក់ និងបុរស១២នាក់)។ អ្នកផ្ដល់ចម្លើយ២៨នាក់បានចូលរួមក្នុងការអង្កេតស្ដីពីអ្នកទទួលប្រយោជន៍ពីគម្រោង។ ចុងក្រោយ ទីប្រឹក្សាបានធ្វើទស្សនកិច្ចសិក្សានៅទីតាំងផ្ទាល់ចំនួនប្រាំបីលើក និងបានចូលរួមក្នុងវេទិកាផ្សព្វផ្សាយតាមខេត្តមួយលើក និងចូលរួមក្នុងសវនាការប្រកាសសាលដីកាក្នុងសំណុំរឿង០០២/០២។

ការវាយតម្លៃត្រូវបានធ្វើឡើង ស្របតាមគោលការណ៍ដូចកំណត់ក្នុងនិយាម និងបទដ្ឋានក្រុមវាយតម្លៃអង្គការសហប្រជាជាតិសម្រាប់ការវាយតម្លៃ និងគោលការណ៍ក្រមសីលធម៌សម្រាប់ការវាយតម្លៃ។ បន្ថែមលើនេះទៀត ទីប្រឹក្សាបានបង្កើតផែនការសុវត្ថិភាព និងហានិភ័យ ជាមួយនឹងតារាងវាយតម្លៃហានិភ័យ ដោយរៀបរាប់អំពីហានិភ័យជាក់លាក់ ព្យសនកម្មសក្ដានុពល និងយុទ្ធសាស្ត្រសម្រាល។

អ្នកផ្ដល់ចម្លើយក្នុងការវាយតម្លៃនេះ រួមមានអ្នកពាក់ព័ន្ធជាច្រើននាក់ ក្នុងនោះមាន ដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងរបស់ពួកគាត់ សាច់ញាតិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដៃគូក្នុងសហគមន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី អាជ្ញាធរមូលដ្ឋាន ដូចជា ប្រធានភូមិ និងតំណាងមកពីគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ និងមេធាវីអន្តរជាតិ រួមមាន មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អ្នកផ្ដល់សេវាកម្ម ដូចជា អ្នកជំនាញផ្នែកអប់រំ និងបុគ្គលិកមណ្ឌលសុខភាព បុគ្គលិកអង្គភាពគាំពារជនរងគ្រោះ និងបុគ្គលិកអង្គការចិត្តសង្គម អន្តរវប្បធម៌ និងតំណាងមកពីអ.វ.ត.ក ក្រសួងនានា និងអង្គការមិនមែនរដ្ឋាភិបាល។

លទ្ធផលត្រូវបានវិភាគ និងផ្ទៀងផ្ទាត់ជាមួយលទ្ធផលតាមដានរបស់គម្រោង។ សេចក្ដីព្រាងរបាយការណ៍នេះត្រូវបានពិភាក្សាក្នុងចំណោមអង្គការដៃគូ ហើយព័ត៌មានត្រឡប់ទាំងអស់ត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍សំណៅចុងក្រោយ។

ជួនកាល ការទៅជួបអ្នកផ្ដល់ព័ត៌មានប្រឈមបញ្ហាខ្លះដែរ ដោយសារតែព័ត៌មានសម្រាប់ទំនាក់ទំនងជាមួយដើមបណ្ដឹងរដ្ឋប្បវេណីនៅមានកម្រិត និងការបំពេញការងារមានលក្ខណៈមមាញឹកខ្លាំងដោយសារការដាក់ផែនការចំពេលការប្រកាសសាលក្រមរបស់អ.វ.ត.ក។ ទីប្រឹក្សាវាយតម្លៃបានប្រមាណមើលឃើញឧបសគ្គ និងហានិភ័យបន្ថែមមួយចំនួនទៀត នៅមុនពេលចុះប្រមូលទិន្នន័យនៅតាមមូលដ្ឋាន ក្នុងនោះរួមមានករណីការសួរនាំពីសំណាក់អាជ្ញាធរមូលដ្ឋាន បញ្ហាអំណាច និងយេនឌ័រ ក្នុងអំឡុងពេលពិភាក្សាជាក្រុម និងកង្វះឯកជនភាពក្នុងសហគមន៍។ យ៉ាងណាមិញ ឧបសគ្គទាំងនេះអាចត្រូវបានកាត់បន្ថយបាន តាមរយៈការរៀបចំផែនការដ៏ប្រុងប្រយ័ត្ន។

# សេចក្តីសន្និដ្ឋាន និងគំហើញសំខាន់ៗ

## ភាពពាក់ព័ន្ធរបស់គម្រោង

គម្រោងនេះ គឺជាកិច្ចខិតខំប្រឹងប្រែងដ៏ពិសេស និងដែលមនុស្សផងទាំងពួងកំពុងទន្ទឹងរង់ចាំតាមដានក្នុងបរិបទយុត្តិធម៌អន្តរកាលនៅកម្ពុជា ដោយសារតែសារៈសំខាន់របស់វា ដែលត្រូវបានគេចាត់ទុកជា កិច្ចប្រឹងប្រែងខ្នាតធំដំបូងគេបង្អស់ ដើម្បីនាំមកនូវយុត្តិធម៌ និងការជាសះស្បើយជូនជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម។ ចំណុចខ្លាំងទូទៅនៃគម្រោងនេះ គឺលក្ខណៈរាប់បញ្ចូល និងភាពទូលំទូលាយរបស់វា។ គម្រោងចាត់វិធានការដ៏ធំទូលំទូលាយ ក្នុងការកំណត់តម្រូវការ និងផលប្រយោជន៍របស់ក្រុមគោលដៅ តាមរយៈវដ្តគម្រោង។ ការតាមដានក្នុងគម្រោងនេះ មានលក្ខណៈពេញលេញ ដោយឆ្លើយតបទៅនឹងបញ្ហាប្រឈមគន្លឹះៗនៅក្នុងដំណាក់កាលទីមួយ។

ការសន្ទត់របស់គម្រោងមានលក្ខណៈប្រាកដនិយម ហើយការរួមផ្សំគ្នានៃសេវាកម្មផ្សេងៗក្នុងវិស័យយុត្តិធម៌ ការចងចាំ និងសុខភាពផ្លូវចិត្ត ដែលមានលក្ខណៈឆ្លើយតបយ៉ាងច្បាស់ទៅនឹងបរិបទ និងតម្រូវការជាក់ស្តែងរបស់ជនរងគ្រោះ។ ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនបន្តគាំទ្រដល់អ.វ.ត.ក ក៏ដូចជា ការនិទានរឿង និងការចងចាំ និងផ្ទុះបញ្ហាំងអំពីតម្រូវការចង់បន្តចែករំលែកបទពិសោធន៍របស់ពួកគាត់តទៅទៀតជាមួយកូនចៅជំនាន់ក្រោយៗ។

បើទោះជាដើមបណ្តឹងរដ្ឋប្បវេណីមានបំណងប្រាថ្នាចង់ទទួលបានសំណងជាថវិកាក្តី ពួកគាត់ភាគច្រើននៅក្នុងគម្រោងនេះយល់អំពីលទ្ធភាពរបស់អ.វ.ត.ក និង ទស្សនទានអំពីសំណង "ផ្លូវចិត្តនិងសមូហភាព"។

ដើមបណ្តឹងរដ្ឋប្បវេណីមានតម្រូវការបន្ថែមទៀត ក្នុងវិស័យអប់រំ ការអប់រំកូនចៅ ការកាត់បន្ថយភាពក្រីក្រ និងការថែទាំសុខភាព ពិសេស អ្នកដែលទទួលខុសត្រូវមើលថែទាំចៅៗ។ យ៉ាងណាមិញ ដោយសារតែចន្លោះប្រហោងក្នុងការផ្តល់សេវាកម្ម មិនរំពឹងថា គម្រោងអាចឆ្លើយតបតាមតម្រូវការទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ។

គម្រោងបានរួមចំណែកដល់ការផ្លាស់ប្តូរខ្លះដែរ បើនិយាយអំពីសមត្ថភាពស្ត្រីក្នុងការដោះស្រាយវិវាទក្នុងគ្រួសារ និងចូលរួមក្នុងការសម្រេចចិត្ត។ យ៉ាងណាមិញ គម្រោងនៅថ្ងៃអនាគតនឹងដាក់បញ្ចូលគំនិតផ្តួចផ្តើមបន្ថែម ដើម្បីជួយឲ្យមានការផ្លាស់ប្តូរក្នុងរចនាសម្ព័ន្ធ និងសន្ទុះអំណាច សម្រាប់ការពង្រឹងការអនុវត្តពាក់ព័ន្ធនឹងវិសមភាពយេនឌ័រ។

# ប្រសិទ្ធភាព

## លទ្ធផលទី១

បុគ្គលិកអ.វ.ត.ក មេធាវីកម្ពុជា អង្គការដៃគូ និងមន្ត្រីប៉ូលិស មានការយល់ដឹងកាន់តែប្រសើរអំពីបញ្ហាយេនឌ័រ និងកាន់តែមានលក្ខណៈរសើបទៅនឹងតម្រូវការរបស់ជនរងគ្រោះពីអំពើហិង្សាផ្លូវភេទ។ ជនបង្គោលយេនឌ័រដើរតួនាទីដ៏សំខាន់ ក្នុងការធ្វើឲ្យប្រសើរឡើងនូវសមភាពយេនឌ័រ និងភាពរសើបយេនឌ័រនៅអ.វ.ត.ក។ យ៉ាងណាមិញ ពួកគេពុំបានចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយរបស់គម្រោងនោះទេ។

កិច្ចប្រជុំបណ្តាញការងារខ្នាតធំជាច្រើនបានជម្រុញឲ្យមានការចែករំលែកចំណេះដឹង និងកាប្រាស្រ័យទាក់ទងល្អចំណោមអង្គការពាក់ព័ន្ធផ្សេងៗក្នុងវិស័យនេះ។

## លទ្ធផលទី២

ដើមបណ្តឹងរដ្ឋប្បវេណីមានតំណាងផ្លូវច្បាប់ត្រឹមត្រូវនៅចំពោះមុខតុលាការ និងទទួលបានសេវាផ្នែកចិត្តសាស្ត្រ និងភស្តុភារគ្រប់គ្រាន់ ដើម្បីធានាបាននូវការចូលរួមប្រកបដោយខ្លឹមសាររបស់ពួកគាត់នៅ អ.វ.ត.ក។

សកម្មភាពផ្សព្វផ្សាយ ដែលអនុវត្តក្នុងគម្រោង បានផ្តល់ព័ត៌មានទាក់ទងនឹងច្បាប់ប្រកបដោយប្រសិទ្ធភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើន ដោយមានកំណើនយល់ដឹងយ៉ាងច្បាស់លាស់អំពីដំណើរការនីតិវិធីនៅអ.វ.ត.ក។ បន្ថែមលើនេះទៀត តំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគម្រោងនេះទទួលបានការបណ្តុះបណ្តាលយ៉ាងទូលំទូលាយអំពីចំណេះដឹងលើបញ្ហាយេនឌ័រ និងសុខភាពផ្លូវចិត្ត។

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលថវិកាឧបត្ថម្ភពីគម្រោងបានផ្តល់ព័ត៌មាន និងសេវាកម្មផ្នែកច្បាប់ប្រកបដោយគុណភាព ដល់កូនក្តីរបស់ខ្លួន។ យ៉ាងណាមិញ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដែលបំពេញការងារដោយស្ម័គ្រចិត្ត និងកូនក្តីរបស់ពួកគាត់ជាច្រើនបានស្នើសុំការប្រឹក្សាយោបល់ផ្នែកច្បាប់បន្ថែមទៀត។

ដើមបណ្តឹងរដ្ឋប្បវេណី បានចូលរួមយ៉ាងសកម្មក្នុងគំនិតផ្តួចផ្តើមនានា ដែលត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការតស៊ូមតិ និងការចែករំលែកចំណេះដឹង។ ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនមានអារម្មណ៍ថា អ្នកដទៃបានស្តាប់ពួរឿងរ៉ាវរបស់ពួកគាត់ ហើយជាទូទៅ ពួកគាត់ពេញចិត្តនឹងការចូលរួមក្នុងសកម្មភាពទាំងនោះ។

## លទ្ធផលទី៣

សកម្មភាពលើកកម្ពស់ការយល់ដឹង និងព័ត៌មានដ៏ទូលំទូលាយ (ការតាំងពិពណ៌ចល័ត ការសន្ទនា និងការអប់រំក្នុងសហគមន៍ វេទិកាលើអ៊ីនធឺណេត សម្ភារៈផ្សព្វផ្សាយ កម្មវិធីវិទ្យុ និងវីឌេអូឃ្លីប ការប្រជុំបណ្ដាញការងារ...ជាដើម) បានធានាការទទួលបានប្រកបដោយប្រសិទ្ធភាពនូវព័ត៌មានអំពីអំពើហិង្សាផ្លូវភេទដែលកើតមានក្នុងរបបខ្មែរក្រហម សិទ្ធិស្ត្រី និង ឧទាហរណ៍ "ការអនុវត្តល្អៗ" សម្រាប់ការងារពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល ដែលមានលក្ខណៈរសើបយេនឌ័រ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

សកម្មភាពតស៊ូមតិ និងបណ្ដាញបានចូលរួមចំណែកដ៏សំខាន់ដល់ការដាក់បញ្ចូលសេវាកម្មនានាជូនដល់ជនរងគ្រោះពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ក្នុងផែនការសកម្មភាពជាតិលើកទីបី ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី (NAPVAW III)។ អាជ្ញាធរនៅថ្នាក់សហគមន៍ ជាពិសេស មានការយល់ដឹងកាន់តែច្រើនអំពីអំពើហិង្សាផ្លូវភេទ ក្នុងរបបខ្មែរក្រហម ហើយកាន់តែមានការចាប់អារម្មណ៍ទៅលើតម្រូវការរបស់អ្នកនៅរស់រានមានជីវិត។

គម្រោងបានបង្កើតផលឥទ្ធិពលនៅច្រើនស្រទាប់ ក្នុងនោះរួមមានទាំងការរៀបចំគម្រោងបន្ថែមរបស់សង្គមស៊ីវិល សម្រាប់បម្រើជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម និងបទយកការណ៍ដ៏ទូលំទូលាយពីសំណាក់អ្នកសិក្សាស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយអំពីប្រធានបទនេះ។

## លទ្ធផលទី៤

ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាស្ត្រី និងជនរងគ្រោះពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមផ្សេងៗទៀតទទួលបានសេវាកម្មផ្នែកចិត្តសាស្ត្រសមស្របតាមវប្បធម៌ និងសិទ្ធិមនុស្ស (ការព្យាបាលតាមបែបសក្ខីកម្ម/និទានរឿង ក្រុមជួយខ្លួនឯង ការព្យាបាល និងការវាយតម្លៃចិត្តសាស្ត្រ ការផ្ដល់ប្រឹក្សាតាមទូរស័ព្ទ...ជាដើម) បានធ្វើឱ្យកាន់តែប្រសើរនូវយុទ្ធសាស្ត្រដោះស្រាយបញ្ហា ការជាសះស្បើយ និងសុខុមាលភាពផ្លូវចិត្តរបស់ពួកគាត់។

ការបណ្ដុះបណ្ដាលផ្ទៃក្នុង ដ៏ទូលំទូលាយបានពង្រឹងប្រកបដោយប្រសិទ្ធភាពនូវចំណេះដឹងអំពីយេនឌ័រ និងជំនាញផ្នែកព្យាបាល ក្នុងចំណោមបុគ្គលិករបស់អង្គការធីភីអូ ដែលចូលរួមក្នុងគម្រោង។

ការវាយតម្លៃសហគមន៍ និងការបណ្ដុះបណ្ដាលបុគ្គលជាធនធានក្នុងសហគមន៍បានជួយពង្រឹងសកម្មភាពក្នុងសហគមន៍ និងជួយពង្រឹងដល់ភាពជាម្ចាស់របស់អ្នកទទួលប្រយោជន៍ពីគម្រោងទៅលើបទអន្តរាគមន៍ផ្នែកចិត្តសាស្ត្ររបស់គម្រោង។ យ៉ាងណាមិញ ចាំបាច់ត្រូវមានការបណ្ដុះបណ្ដាល និងការគាំទ្របន្តទៀត។

ការផ្តួចផ្តើមបង្កើតឲ្យមានក្រុមប្រាក់សន្សំ គឺពិតជាវិធីសាស្ត្រដ៏សមស្រប និងប្រកបដោយជោគជ័យខ្ពស់ ក្នុងការធានាបាននូវការថែទាំសុខភាពដោយឥតគិតថ្លៃរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសហគមន៍ ដែលបានជ្រើសរើស។

## ប្រសិទ្ធផល

ការអនុវត្តគម្រោងក្នុងវិសាលភាព និងទំហំនេះ គឺជាសមិទ្ធិផលដ៏អស្ចារ្យមួយក្នុងបរិបទយុត្តិធម៌អន្តរកាលនៅកម្ពុជា។

ឧបសគ្គចំពោះការអនុវត្តប្រកបដោយប្រសិទ្ធភាព ភាគច្រើន គឺពាក់ព័ន្ធនឹងបញ្ហាប្រឈមពីខាងក្រៅ និងធនធានមនុស្សដ៏មានកម្រិត។ យ៉ាងណាមិញ ការអនុវត្តគ្រប់គ្រងល្អៗ ក៏ដូចជា ជំនាញកម្រិតខ្ពស់របស់អង្គការដៃគូ និងការប្តេជ្ញាចិត្ត ពិតជាអាចធានាបាននូវលទ្ធផលល្អ និងការចំណាយថវិកាទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

## ឥទ្ធិពល

គម្រោងនេះ គឺជាកិច្ចខិតខំប្រឹងប្រែងដ៏ពិសេសមួយ ក្នុងការធ្វើឲ្យអ.វ.ត.ក និងដំណើរការយុត្តិធម៌របស់ខ្លួន កាន់តែជ្រួតជ្រាបដល់អ្នកនៅរស់រានមានជីវិត តាមរយៈតំណាងផ្នែកច្បាប់ និងព័ត៌មាន ការគាំទ្រផ្នែកភស្តុភារ ការបណ្តុះបណ្តាលយេនឌ័រ ការលើកកម្ពស់ការយល់ដឹង និងការគាំទ្រផ្នែកចិត្តសាស្ត្រ។

អ្នកទទួលប្រយោជន៍ពីគម្រោងជ្រួតជ្រាបយ៉ាងទូលំទូលាយអំពីដំណើរការយុត្តិធម៌អន្តរកាល និងជាទូទៅ មានការពេញចិត្តយ៉ាងខ្លាំងនឹងការចូលរួមរបស់ពួកគាត់នៅអ.វ.ត.ក និងសេវាកម្មរបស់គម្រោង។ ត្បិតដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនចង់ទទួលបានសំណងហិរញ្ញវត្ថុ ពួកគាត់យល់ដឹងយ៉ាងច្បាស់អំពីលទ្ធភាពរបស់អ.វ.ត.ក ហើយនៅតែពេញចិត្តនឹងបទអន្តរាគមន៍របស់គម្រោង។

គម្រោងបង្កើតឲ្យមានការផ្លាស់ប្តូរវិជ្ជមានដ៏ជាក់ច្បាស់ ក្នុងជីវិតរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាក្រុមគោលដៅ ពិសេស លើការគ្រប់គ្រងជំងឺតានតឹងក្នុងអារម្មណ៍ និងភាពរឹងប៉ឹងផ្នែកស្មារតី ការប្រាស្រ័យទាក់ទងអន្តរបុគ្គល និងសង្គម ការគាំទ្ររបស់សហគមន៍ និងក្រុមគ្រួសារ និង មួយចំណែកទៀត គឺការទទួលបានការថែទាំសុខភាព។

ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដែលជាអ្នកទទួលប្រយោជន៍ផ្ទាល់ពីគម្រោង ទទួលបានសេវាកម្មកម្រិតខ្ពស់ បើធៀបនឹងអ្នកនៅរស់រានមានជីវិតផ្សេងៗទៀត ដែលកើតមានការមិនពេញចិត្ត ដោយសារការមិនរាប់បញ្ចូលពួកគាត់ក្នុងគម្រោង។ អ្នកពាក់ព័ន្ធភាគច្រើនក្នុងសហគមន៍គាំទ្រការនិទានរឿង និងការចងចាំ ពាក់ព័ន្ធនឹងសម័យខ្មែរក្រហម ប៉ុន្តែអ្នកខ្លះពេញចិត្តនឹងរក្សានៅស្ងាត់ស្ងៀមវិញដោយសារតែភ័យខ្លាចកើតមានជម្លោះថ្មីៗទៀត។

## និរន្តរភាព

ការបង្កើនចំណេះដឹងអំពីយេនឌ័រ តាមរយៈគម្រោងនេះ គឺមានសារៈសំខាន់ទាំងនៅថ្នាក់សហគមន៍ និងថ្នាក់ជាតិ។ ស្ថាប័នក្នុងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់សហគមន៍កាន់តែផ្ដោតអារម្មណ៍ថែមទៀតដល់តម្រូវការរបស់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ ក្នុងរបបខ្មែរក្រហម។ យ៉ាងណាមិញ មានចំណាប់អារម្មណ៍តិចតួចទៅលើការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់ខេត្តសម្រាប់ជាប្រយោជន៍ដល់អ្នកនៅរស់រានមានជីវិត។

ធនធានក្នុងសហគមន៍ត្រូវបានកសាងប្រកបដោយប្រសិទ្ធភាព។ យ៉ាងណាមិញ នៅតែមានតម្រូវការសម្រាប់ការបណ្ដុះបណ្ដាលបន្ត និងការផ្ដល់ប្រាក់កម្ចីខ្នាតតូច ដើម្បីបន្តរក្សាឲ្យបាននូវសមិទ្ធផលគម្រោង។

ការផ្ដួចផ្ដើមបង្កើតក្រុមប្រាក់សន្សំ សម្រាប់ទូទាត់ថ្លៃធ្វើដំណើររបស់អ្នកនៅរស់រានមានជីវិតមកកាន់មណ្ឌលសុខភាព គឺជាការចូលរួមចំណែកដ៏ធំធេងមួយ ក្នុងការធ្វើឲ្យប្រសើរឡើងនូវការថែទាំសុខភាពសម្រាប់ជនរងគ្រោះពីអំពើហិង្សាផ្លូវភេទ ដែលជាជនចាស់ជរា។

## ការអភិវឌ្ឍចំណេះដឹង

គម្រោងបានចូលរួមយ៉ាងសំខាន់ដល់ការចងក្រងទុកជាឯកសារនូវសកម្មភាពគម្រោង និងចំណេះដឹងថ្មីៗ និងបានចែករំលែកបទពិសោធន៍របស់ខ្លួន តាមរយៈមធ្យោបាយផ្សេងៗ។

## បទពិសោធន៍ដែលបានរៀនសូត្រ

- តុលាការអន្តរជាតិ ដែលចង់បានការចូលរួមពីដើមបណ្ដឹងរដ្ឋប្បវេណី និងចង់បានកេរ្តិ៍តំណែលវិជ្ជមានសម្រាប់អ្នកដែលពាក់ព័ន្ធ ទាមទារឲ្យមានវិធីសាស្ត្រមួយ តែមានច្រើនមុខព្រួញ ជាមួយនឹងសេវាកម្មដ៏ទូលំទូលាយក្នុងការងារផ្សព្វផ្សាយ ការផ្ដល់ប្រឹក្សា និងតំណាងផ្នែកច្បាប់ ក្នុងនោះរួមមានទាំងការធ្វើដំណើរទៅចូលរួមសវនាការជំនុំជម្រះក្ដី ការគាំទ្រផ្នែកចិត្តសាស្ត្រ ការចងចាំ និងការនិទានរឿង ក្នុងចំណោមសេវាកម្មផ្សេងៗទៀត។ វិធីសាស្ត្របែបនេះទាមទារនូវសហប្រតិបត្តិការដ៏ទូលំទូលាយពីសំណាក់ស្ថាប័នរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដែលជាអង្គការមិនមែនរដ្ឋាភិបាលជាច្រើនខុសៗគ្នា និងការបង្កើតឲ្យមានជាយន្តការរាយការណ៍ និងបណ្ដាញការងារ។
- ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាមទារនូវវិធីសាស្ត្រយូរអង្វែងមួយ និងការរួមចំណែកប្រកបដោយចីរភាព ដើម្បីបង្ការការមិនពេញចិត្តរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាការគំរាមកំហែងដល់កេរ្តិ៍តំណែលជាវិជ្ជមានរបស់តុលាការ។
- វិធានការយុត្តិធម៌អន្តរកាល សម្រាប់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទទាមទារនូវទស្សនវិស័យយេនឌ័រមួយ ក្នុងការងារប្រតិបត្តិការ និងនីតិវិធី និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយ ក្នុងការងារបញ្ជ្រាបយេនឌ័រ ក្នុងនោះរួមមានទាំង ការបណ្ដុះបណ្ដាលអំពីយេនឌ័រដល់បុគ្គលពាក់ព័ន្ធផង។ បទពិសោធន៍ និងក្ដីបារម្ភរបស់ស្ត្រីគួរយកធ្វើជាអាទិភាពក្នុងការរៀបចំ ការអនុវត្ត និងការវាយតម្លៃកម្មវិធីយុត្តិធម៌អន្តរកាលណាមួយ។
- ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាមទារការផ្សព្វផ្សាយ ដែលងាយនឹងទទួលបាន និងងាយយល់សម្រាប់អ្នកនៅរស់រានមានជីវិត។ ការងារផ្សព្វផ្សាយគួរចាប់យកដើមបណ្ដឹងរដ្ឋប្បវេណីជាគោលដៅ ប៉ុន្តែក៏ត្រូវរាប់បញ្ចូលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងទៀតផងដែរ។

- ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជំនុំជម្រះជាលក្ខណៈអន្តរជាតិទាមទារសេវាកម្មដែលអាចឆ្លើយតបទៅនឹងតម្រូវការជីវភាព និងសុខភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពិសេសសម្រាប់អ្នកនៅរស់រានមានជីវិតដែលមានបទពិសោធន៍ព្យសនកម្មលើរូបរាងកាយ ឬការបាត់បង់ទ្រព្យសម្បត្តិ។
- ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាមទារបទអន្តរាគមន៍ចិត្តសាស្ត្រ ដែលសមស្របទៅតាមវប្បធម៌ និងសិទ្ធិមនុស្ស ដោយផ្តោតលើ ក្រុមជួយខ្លួនឯង និងការពង្រឹងការផ្សះផ្សាសង្គម។ សកម្មភាពពាក់ព័ន្ធនឹងការគាំទ្រផ្នែកចិត្តសាស្ត្រគួរដាក់បញ្ចូលការអនុវត្តថ្មីៗ ដើម្បីជម្រុញការនិទានរឿង ដូចជាវិធី “ព្យាបាលតាមបែបផ្តល់សក្ខីកម្ម” នៅកម្ពុជា។
- គំនិតផ្តួចផ្តើមអំពីការនិទានរឿង និងការចងចាំ គួរយកជាអាទិភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងគួរផ្តោតតែលើវិធីសាស្ត្រចូលរួម ដែលអនុញ្ញាតឲ្យមានការរាប់បញ្ចូលអ្នកនៅរស់រានមានជីវិតផ្សេងៗទៀត និងសមាជិកសហគមន៍ ពិសេសកូនចៅជំនាន់ក្រោយ។ បន្ថែមលើនេះទៀត វាជារឿងសំខាន់ដែលត្រូវលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជម្រុញឲ្យមានការយល់ដឹងអំពីអំពើឃោរឃៅនៅអតីតកាល និងការបង្ការមិនឲ្យមានអំពើហិង្សាថ្មីៗទៀតកើតមាន។
- ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាមទារធនធានហិរញ្ញវត្ថុមានចីរភាព ដោយតុលាការ បន្ថែមលើមូលនិធិពីខាងក្រៅ។ ការងារនេះទាមទារនូវការវាយតម្លៃដ៏ទូលំទូលាយមួយអំពីតម្រូវការរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងថ្លៃចំណាយពាក់ព័ន្ធ។ មធ្យោបាយមួយ ក្នុងការធានាបាននូវថវិកា គឺអាចជាការបង្កើតឲ្យមាននូវមូលនិធិបម្រុងមួយ ដូចបង្ហាញក្នុងបរិបទយុត្តិធម៌អន្តរកាលផ្សេងៗទៀត។
- ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាមទារការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេស សម្រាប់ការបង្កើតឲ្យមានសមាគមជនរងគ្រោះ បណ្តាញដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមសហគមន៍ ដើម្បីជម្រុញការតស៊ូមតិ និងការពង្រឹងអំណាច។
- ដើម្បីធានាបាននូវទំនាក់ទំនងនៃកម្មវិធីមួយ វិធានការយុត្តិធម៌អន្តរកាលទាមទារនូវការវាយតម្លៃអំពីតម្រូវការរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុន និងក្នុងអំឡុងវដ្តនៃគម្រោង ពិសេស នៅពេលរៀបចំគម្រោងផ្តល់សំណង។ ដូចគ្នាដែរ ភាពជាម្ចាស់របស់អ្នកនៅរស់រានមានជីវិតអាចត្រូវបង្កើនប្រកបដោយប្រសិទ្ធភាព តាមរយៈការបណ្តុះបណ្តាល និងការគាំទ្រដល់តំណាងជនរងគ្រោះ ឬបុគ្គលទំនាក់ទំនងនៅតាមសហគមន៍។ តំណាងទាំងនេះក៏អាចត្រូវបានបណ្តុះបណ្តាលផងដែរអំពីការដោះស្រាយវិវាទ ការប្រាស្រ័យទាក់ទងដោយអហិង្សា ការសម្របសម្រួលកិច្ចសន្ទនា និងការគាំទ្រសុខភាពផ្លូវចិត្ត។

- ក្តីរំពឹងទុកដែលមិនប្រាកដនិយម និងការមិនពេញចិត្ត ឧទាហរណ៍ ដែលកើតឡើងក្នុងចំណោមអ្នកដាក់ពាក្យដែលមិនត្រូវបានតុលាការទទួលស្គាល់ ឬជនរងគ្រោះផ្សេងទៀត អាចត្រូវបានកាត់បន្ថយតាមរយៈការប្រាស្រ័យទាក់ទង និងព័ត៌មានដ៏ទូលំទូលាយអំពីព្រំដែននៃវិធានការយុត្តិធម៌អន្តរកាល។

# អនុសាសន៍សំខាន់ៗ

## ភាពពាក់ព័ន្ធនៃគម្រោង

វិធីសាស្ត្រនៃការបង្កើតឲ្យមានភាពជាដៃគូ និងការប្រឹក្សាយោបល់ជាមួយអ្នកទទួលប្រយោជន៍ពីគម្រោង ក្នុងគ្រប់ដំណាក់កាលនៃវដ្តគម្រោង ពិតជាធានាបាននូវទំនាក់ទំនងរបស់គម្រោង និងគួរត្រូវបានប្រើប្រាស់ជាការអនុវត្តដ៏ប្រពៃមួយ ក្នុងបទអន្តរាគមន៍ដូចគ្នានេះ។

លទ្ធផលបានមកពីការវាយតម្លៃនេះបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនបន្តគាំទ្រអ.វ.ត.ក ក៏ដូចជា សកម្មភាពនិទានរឿង និងការចងចាំ។ អ្នកផ្តល់ចម្លើយភាគច្រើនវាយតម្លៃខ្ពស់ទៅលើ ការលើកកម្ពស់ការយល់ដឹងប្រកបដោយចីរភាព និងគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងការអប់រំ ដោយផ្តោតជាពិសេសទៅលើការចូលរួមរបស់យុវជន។

គម្រោងយុត្តិធម៌អន្តរកាលអនាគតអាចដាក់បញ្ចូលសេវាកម្មបន្ថែម ដូចជា ការបង្កើនប្រាក់ចំណូល ការអប់រំជីវិតគ្រួសារ និងការថែទាំសុខភាព។

ទម្រង់ជាច្រើនប្រភេទនៃអំពើហិង្សាផ្លូវភេទ ដែលប្រព្រឹត្តចំពោះជនរងគ្រោះនៅក្នុងរបបខ្មែរក្រហមមានលក្ខណៈទូទៅដូចគ្នាទាំងអស់នៅទូទាំងប្រទេសកម្ពុជា ដែលនេះចង្អុលបង្ហាញឲ្យឃើញថា ចាំបាច់ត្រូវឲ្យមានបទអន្តរាគមន៍នៅថ្ងៃអនាគត ដែលមានលក្ខណៈកាន់តែប្រសើរឡើង ដើម្បីធានានូវសិទ្ធិ ទំនួលខុសត្រូវ និងឱកាសស្មើគ្នារវាងជនរងគ្រោះស្ត្រី និងជនរងគ្រោះបុរស។

## ប្រសិទ្ធភាព

### លទ្ធផលទី១

អ្នកទទួលបន្ទុកយេនឌ័រគួរទទួលបានពេលវេលា ទ្រព្យសម្បត្តិ និងធនធានចាំបាច់ ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងសកម្មភាពផ្សព្វផ្សាយរបស់តុលាការ។ ជាជម្រើសផ្សេងមួយទៀត យើងអាចពិចារណាបង្កើតឲ្យមាននូវមុខតំណែងបន្ថែមទៀតសម្រាប់អ្នកជំនាញយេនឌ័រ ដែលធានាដល់ការបញ្ជ្រាបយេនឌ័រក្នុងការងារផ្សព្វផ្សាយរបស់តុលាការ។

កិច្ចប្រជុំ “បណ្តាញការងារផ្តល់ជំនួយផ្នែកច្បាប់” បន្ថែមអាចត្រូវបានប្រើប្រាស់ ដើម្បីជួយជម្រុញដល់យន្តការបញ្ជូន និងដើម្បីរៀបចំកម្មវិធី ដែលមានលក្ខណៈសហប្រតិបត្តិការ សម្រាប់ជាប្រយោជន៍របស់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ។

**លទ្ធផលទី២**

បើទោះជាមានការគាំទ្រផ្នែកច្បាប់ដ៏ទូលំទូលាយពីសំណាក់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីខ្លះក្តី ធនធានបន្ថែមទៀតទាមទារឲ្យមានជាចាំបាច់ ដើម្បីពង្រឹងគុណភាពការផ្តល់សេវាកម្មរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លទ្ធផលទី៣**

ដៃគូអនុវត្តគម្រោងគួរបន្តសហការជាមួយក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិសម្រាប់ស្ត្រី ដើម្បីធ្វើការតស៊ូមតិឲ្យមានការដាក់បញ្ចូលសេវាកម្មផ្សេងៗ សម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ក្នុងរបបខ្មែរក្រហម។

**លទ្ធផលទី៤**

បុគ្គលដែលជាធនធានប្រចាំក្នុងសហគមន៍ តំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសមាជិកក្រុមជួយខ្លួនឯង ដែលមានការប្តេជ្ញាចិត្តខ្ពស់ គួរទទួលបានការបណ្តុះបណ្តាលបន្ថែម មធ្យោបាយអនុវត្តន៍ (ឧ. បដាផ្សព្វផ្សាយ ឌីវីឌី អាវយឺត នាមប័ណ្ណ រឿងកុនអប់រំ... ជាដើម) និងការឧបត្ថម្ភហិរញ្ញវត្ថុ ដើម្បីរៀបចំអនុវត្តសេវាកម្មនៅតាមសហគមន៍ នៅក្រោយពេលបញ្ចប់គម្រោង។

ក្នុងគម្រោងជាក់លាក់ណាមួយ ដៃគូអនុវត្តគម្រោងអាចរៀបចំការវាយតម្លៃ ដែលមានលក្ខណៈកាន់តែទូលំទូលាយមួយស្តីពីអ្នកផ្តល់សេវាកម្មប្រចាំភូមិភាគ និងមូលដ្ឋាន ដើម្បីជួយសម្របសម្រួលដល់ការបញ្ជូនជនរងគ្រោះទៅទទួលសេវាកម្មផ្សេងៗ។ ដើម្បីដោះស្រាយបញ្ហាថ្លៃចំណាយលើការធ្វើដំណើរ ក្រុមប្រាក់សន្សំ ដូចជាក្រុមប្រាក់សន្សំប្រើប្រាស់ក្នុងគម្រោងនេះ អាចក្លាយជាដំណោះស្រាយសមស្រប និងដ៏ស័ក្តិសិទ្ធិមួយ។

## ប្រសិទ្ធផល

ក្នុងបទអន្តរាគមន៍ដូចគ្នានេះ ដៃគូអនុវត្តគម្រោងគួររៀបចំធ្វើការវាយតម្លៃឲ្យកាន់តែដ៏ទូលំទូលាយមួយស្តីពីកិច្ចខិតខំប្រឹងប្រែងចាំបាច់នានា។ នេះនឹងអនុញ្ញាតឲ្យមានវត្ថុបំណងកាន់តែប្រាកដនិយមថែមទៀត បើនិយាយអំពីធនធានមនុស្ស។

## ឥទ្ធិពល

ម្ចាស់ជំនួយអន្តរជាតិ និងរដ្ឋាភិបាលគួរបន្តគាំទ្រផ្នែកហិរញ្ញវត្ថុដល់អង្គភាពគាំពារជនរងគ្រោះរហូតដល់អ.វ.ត.ក បិទទ្វារ។

ម្ចាស់ជំនួយគួរពង្រីកការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ខ្លួនដល់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធមួយចំនួនក្រោយពេលតុលាការបិទទ្វារ។ នេះនឹងជួយឱ្យអង្គការទាំងនេះគាំទ្រ និងផ្តល់សេវាកម្មបន្តប្រកបដោយចីរភាពដល់ដើមបណ្តឹងរដ្ឋប្បវេណី។

អង្គការមិនមែនរដ្ឋាភិបាលគួរផ្តល់ព័ត៌មានផ្នែកច្បាប់ ការគាំទ្របែបចិត្តសង្គមស្របតាមសិទ្ធិមនុស្ស និងការចងចាំ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះក្នុងរបបខ្មែរក្រហមផ្សេងៗទៀត។ សេវាកម្មគួររាប់បញ្ចូលផងដែរនូវការថែទាំសុខភាព និងសកម្មភាពបង្កើនប្រាក់ចំណូល និងគួរចាប់យកជនរងគ្រោះក្នុងរបបខ្មែរក្រហមច្រើនសណ្ឋានធ្វើជាគោលដៅ។

ក្នុងករណីអ.វ.ត.ក បិទទ្វារ អង្គភាពគាំពារជនរងគ្រោះ និងដៃគូអនុវត្តគម្រោងគួររៀបចំយុទ្ធនាការផ្តល់ព័ត៌មាន ដើម្បីកាត់បន្ថយការខកចិត្ត ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤។

## និរន្តរភាព

ដើម្បីបន្តរក្សាបញ្ហាអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមនៅលើរបៀបវារៈ ដៃគូអនុវត្តគម្រោងគួរបន្តថែរក្សា និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់គម្រោង និងបន្តពង្រឹងបណ្តាញការងារ ដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះពីរបបខ្មែរក្រហម។

ការចូលរួម និងការគាំទ្ររបស់រដ្ឋាភិបាល ដែលមានលក្ខណៈកាន់តែប្រសើរ ក្នុងការបង្កើតយុទ្ធសាស្ត្រនៅថ្នាក់ខេត្ត អាចជួយធ្វើការផ្តល់សេវាកម្មកាន់តែល្អ ជូនដល់ជនរងគ្រោះពីរបបខ្មែរក្រហម។

ដោយទទួលស្គាល់នូវមូលនិធិដែលមានកម្រិត មានចន្លោះប្រហោងដែលត្រូវពង្រឹងបន្ថែមដល់សមាគមចាស់ជរា និងក្រុមជួយខ្លួនឯងរបស់គម្រោង ដើម្បីបម្រើដល់របៀបវារៈផ្នែកសេដ្ឋកិច្ច ចិត្តសង្គម និង ការតស៊ូមតិ សម្រាប់សមាជិករបស់ពួកគាត់។

## ការអភិវឌ្ឍចំណេះដឹង

អង្គភាពគាំពារជនរងគ្រោះ និងអង្គការចិត្តសង្គម អន្តរវប្បធម៌គួរបន្តផ្សព្វផ្សាយបទពិសោធន៍ និង "ការអនុវត្តល្អៗ" ទាំងក្រុង និងក្រៅបរិបទយុត្តិធម៌អន្តរកាល។ ឧទាហរណ៍ ដៃគូអនុវត្តគម្រោងអាចធ្វើឲ្យកាន់តែប្រសើរឡើងនូវការផ្លាស់ប្តូរចំណេះដឹង ជាមួយក្រុមសិទ្ធិមនុស្ស និងស្ថាប័នពហុភាគី ដើម្បីដាក់បញ្ចូលការរំញោចយេនឌ័រទៅក្នុងវិស័យយុត្តិធម៌អន្តរកាលរបស់ពួកគេ។

អង្គភាពគាំពារជនរងគ្រោះ និងអង្គការចិត្តសង្គម អន្តរវប្បធម៌គួរចងក្រងទុកជាឯកសារ និងថែរក្សាទុករាល់លទ្ធផល ដែលបានមកពីកិច្ចប្រជុំស្តីពីបណ្តាញការងារផ្តល់ជំនួយផ្នែកច្បាប់។ លទ្ធផលទាំងនេះទទួលបានការកោតសរសើរថា ជាយន្តការដ៏ចម្បងមួយសម្រាប់ការចែករំលែកចំណេះដឹង ហើយបានដាក់បញ្ចូលបទបង្ហាញប្រកបដោយគុណភាពខ្ពស់ជាច្រើនទៀតផង។